រាជរដ្ឋាភិបាលកម្ពុជា
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
Council for the Development of Cambodia

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation-Religion-King

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីវេទិកាថ្នាក់រដ្ឋមន្ត្រីតំបន់អាស៊ីអាគ្នេយ៍របស់អង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD) ឆ្នាំ២០២២

តបតាមការអញ្ជើញរបស់ក្រសួងការបរទេសវៀតណាម ក្រសួងពាណិជ្ជកម្មនិងទេសចរណ៍អូស្ត្រាលី និងអង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD) នារសៀលថ្ងៃចន្ទ ៧រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **សុខ ចិន្តាសោភា** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានចូលរួមក្នុងវេទិកាថ្នាក់រដ្ឋមន្ត្រីតំបន់អាស៊ីអាគ្នេយ៍របស់អង្គការ OECD ឆ្នាំ២០២២ ដែលបានប្រព្រឹត្តទៅពីថ្ងៃទី១៧-១៨ ខែតុលា ឆ្នាំ២០២២ នៅទីក្រុងហាណូយ សាធារណរដ្ឋសង្គមនិយមវៀតណាម។ វេទិកានេះមានការចូលរួមពីឯកឧត្តម **Pham Binh Minh** ឧបនាយករដ្ឋមន្ត្រីប្រចាំការនៃប្រទេសវៀតណាម, ឯកឧត្តម **Bui Thanh Son** រដ្ឋមន្ត្រីក្រសួងការបរទេសនៃប្រទេសវៀតណាម, ឯកឧត្តម **Tim Ayres** អនុរដ្ឋមន្ត្រីទទួលបន្ទុកពាណិជ្ជកម្ម និងកម្មន្តសាលនៃប្រទេសអូស្ត្រាលី, ឯកឧត្តម **Mathias Cormann** អគ្គលេខាធិការអង្គការ OECD, ឯកឧត្តម **ចាយ ណារុធ** ឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសវៀតណាម, និងឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងប្រទេសសមាជិកអង្គការ OECD អាស៊ាន និងវិស័យឯកជន ដែលមានអ្នកចូលរួមផ្ទាល់ និងតាមប្រព័ន្ធវីដេអូ សរុបប្រមាណ ៤០០នាក់។

នៅក្នុងវេទិកានេះ ឯកឧត្តម **សុខ ចិន្តាសោភា** គឺជាវាគ្មិនមួយរូបដែលបានធ្វើបទអន្តរាគមន៍ក្នុងកិច្ចពិភាក្សាថ្នាក់រដ្ឋមន្ត្រីក្រោមប្រធានបទ "**ភាពជាដៃគូរវាងតំបន់អាស៊ីអាគ្នេយ៍ និងអង្គការ OECD ដើម្បីពង្រឹងភាពធន់នៃខ្សែច្រវាក់ផ្គត់ផ្គង់**" ក្នុងចំណោមឥស្សរជនជាន់ខ្ពស់ដទៃទៀតដែលរួមមានដូចជា លោកជំទាវ **Mary Ng** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មអន្តរជាតិ ការជំរុញការនាំចេញ ការអភិវឌ្ឍសេដ្ឋកិច្ចនិងធុរកិច្ចខ្នាតតូចនៃប្រទេសកាណាដា, ឯកឧត្តម **Park Jin** រដ្ឋមន្ត្រីក្រសួងការបរទេសនៃសាធារណរដ្ឋកូរ៉េ, ឯកឧត្តម **Tobias Lindner** រដ្ឋលេខាធិការក្រសួងការបរទេសអាល្លឺម៉ង់, ឯកឧត្តម **Takagi Kei** អនុរដ្ឋមន្ត្រីក្រសួងការបរទេសជប៉ុន, និងឯកឧត្តម **Lim Jock Hoi** អគ្គលេខាធិការអាស៊ាន ជាដើម។

ឯកឧត្តម **សុខ ចិន្តាសោភា** បានថ្លែងដោយសង្កត់ធ្ងន់ពីស្មារតីនៃការរួបរួមគ្នាជាធ្លុងមួយដើម្បីទទួលបាននូវផលប្រយោជន៍រួម។ ឯកឧត្តមបានលើកឡើងដូច្នេះថា "រូបិយប័ណ្ណដ៏មានតម្លៃបំផុតក្នុងខ្សែច្រវាក់ផ្គត់ផ្គង់គឺជាពេលវេលា។ តាមរយៈការប្រើប្រាស់ឌីជីថលភាវូបនីយកម្ម និងម៉ូដែលព្យាករណ៍ខ្សែច្រវាក់ផ្គត់ផ្គង់ យើងនឹងបង្កើតខ្សែច្រវាក់ផ្គត់ផ្គង់ដែលលឿនជាងមុន និងថោកជាងមុន និងអាចជួយសង្គ្រោះជីវិតមនុស្សបាន យ៉ាងហោចណាស់សម្រាប់ខ្សែច្រវាក់ផ្គត់ផ្គង់ក្នុងវិស័យសុខាភិបាល។" ឯកឧត្តម **សុខ ចិន្តាសោភា** ក៏បានថ្លែងថាកម្ពុជាជឿជាក់លើអត្ថប្រយោជន៍នៃកិច្ចសហប្រតិបត្តិការនិងការធ្វើសមាហរណកម្មកាន់តែជិតស្និទ្ធជាមួយប្រទេសនៅក្នុង និងក្រៅតំបន់។ ការប្តេជ្ញារបស់កម្ពុជាក្នុងការជំរុញឌីជីថលភាវូបនីយកម្ម និងវិស័យឡូជីស្ទីកក៏បានឆ្លុះបញ្ចាំងតាមរយៈការផ្តល់នូវការលើកទឹកចិត្តវិនិយោគក្នុងឧស្សាហកម្មឌីជីថល និងការវិនិយោគក្នុងវិស័យឡូជីស្ទីក នៅក្នុងច្បាប់ស្តីពីវិនិយោគដែលបានអនុម័តកាលពីចុងឆ្នាំ២០២១កន្លងទៅ។

"ខ្ញុំជឿជាក់លើថាមពលមនុស្សជាតិ ហើយខ្ញុំជឿថា **ការរួបរួមគ្នាក្នុងភាពជាដៃគូ** នឹងអាចកសាងនូវខ្សែច្រវាក់ផ្គត់ផ្គង់ដែលរឹងមាំនិងមានភាពធន់ជាងមុន ក៏ដូចជាអនាគតមួយដ៏ភ្លឺស្វាង។" នេះជាការលើកឡើងរបស់ឯកឧត្តម **សុខ ចិន្តាសោភា** មុននឹងបញ្ចប់បទអន្តរាគមន៍របស់ឯកឧត្តម។

សូមជម្រាបថា ក្រោមប្រធានបទ "**ការតភ្ជាប់តំបន់÷ ភាពជាដៃគូសម្រាប់ខ្សែច្រវាក់ផ្គត់ផ្គង់ដែលមានភាពធន់ និងប្រកបដោយចីរភាព**"វេទិកាថ្នាក់រដ្ឋមន្ត្រីតំបន់អាស៊ីអាគ្នេយ៍របស់អង្គការ OECD ឆ្នាំ២០២២ នេះបានធ្វើការពិភាក្សាអំពីវិធីសាស្ត្រក្នុងការលើកកម្ពស់ភាពជាដៃគូរវាងអង្គការ OECD និងតំបន់អាស៊ីអាគ្នេយ៍ ដើម្បីបង្កើនភាពធន់នៃខ្សែច្រវាក់ផ្គត់ផ្គង់, ជំរុញពាណិជ្ជកម្មសេរី, ជំរុញការវិនិយោគ និងគាំទ្រការផ្លាស់ប្តូរវិស័យឌីជីថល និងវិស័យបៃតងក្នុងរយៈពេលវែងខាងមុខ។វេទិកានេះផ្តល់ឱកាសសម្រាប់រដ្ឋមន្ត្រី និងអ្នកតំណាងកម្រិតខ្ពស់មកពីបណ្តាប្រទេសសមាជិកអង្គការ OECD ដែលមានចំនួន ៣៨ និងបណ្តាប្រទេសអាស៊ាន ដើម្បីពិភាក្សាអំពីវិធានការជាក់ស្តែងដែលអាស៊ាន និងធុរកិច្ចនិងរដ្ឋាភិបាលនៃប្រទេសសមាជិកអង្គការ OECD អាចសហការគ្នាដើម្បីកែលម្អភាពធន់នៃខ្សែសង្វាក់ផ្គត់ផ្គង់ក្នុងរយៈពេលដ៏ខ្លីខាងមុខនេះ។